# សាលាក្តីខ្មែរក្រហមៈ
# ក្រុមប្រទេសម្ចាស់ជំនួយត្រូវតែទាមទារអោយមានការកែទម្រង់
# មុនពេលសន្យា ផ្តល់ប្រាក់ជំនួយបន្ថែមទៀត

*ដោយ សារា ខូលម៍* (Sara Colm)

*ការជំនុំជំរះក្តីអតីតៈមេដឹកនាំ ខ្មែរក្រហម ដែលអូសបន្លាយពេលជាយូរមកហើយនោះបានចាប់ផ្តើមកាលពីសប្តាហ៍មុនដែលតុលាការបញ្ជាអោយមាន ការសម្តែងឡើងវិញនៅឯអតីតៈគុកទួលស្លែងដែលល្បីខាងអាក្រក់របស់របបនោះ ។គុកទួលស្លែងជាកន្លែងដែលមនុស្សជាងមួយម៉ឺនបួនពាន់នាក់ត្រូវបានគេធ្វើទារុណកម្មនិងពិឃាដក្នុងអំឡុងពេលឆ្នាំ 1975 ដល់ ឆ្នាំ1979។ ប៉ែកខាងបន្ទប់សាវនាការ ប៉ែកខាងបន្ទប់ទស្សនីយភាពអ្នកដែលនៅសេសសល់រស់រានមានជីវិតពីគុកទាំបីនាក់នោះ ត្រូវបានគេនាំអោយឈរទល់មុលគ្នារវាង កាំង គិចអ៊ីវហៅ ឌុច ដែលជាអតីតៈប្រធានគុកទួលស្លែងក្នុងខណៈពេលដែលក្រុមតុលាការ ព្រះអាជ្ញា និង មេធាវី ជាតិ និង អន្តរជាតិ ព្រមទាំងក្រុមអ្នកថតរូបរបស់តុលាការនោះជាច្រើនបានចុះទៅធ្វើទស្សនៈកិច្ចក្នុងគុក ។ ជាផ្លូវការត្រូវបានហៅថាជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សាលាក្តីខ្មែរក្រហមជាតុលាការកូនកាត់មួយដែលមានចៅក្រមខ្មែរភាគច្រើន អង្គុយតាមជួរជាមួយចៅក្រមអន្តរជាតិនិងសហព្រះរាជអាជ្ញាខ្មែរ និងអន្តរជាតិមួយចំនួន ។*

*ឌុចស្ថិតនៅក្នុងចំណោមអតីតៈមេដឹកនាំខ្មែរក្រហមទាំងប្រាំនាក់ដែលកំពុងជាប់ឃុំឃាំងក្រោមការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងឧក្រិដ្ឋកម្មសង្គ្រាមដែលធ្វើអោយប្រជាជនកម្ពុជាជិតពីរលាននាក់បានបាត់បង់ជីវិតក្នុងកំឡុងនៃការដឹកនាំរបស់ពួកគេអស់រយៈពេលជិត4ឆ្នាំ ហើយដែលបានបញ្ចប់ក្នុងឆ្នាំ1979នោះ ។*

កាលពីខែធ្នូរកន្លងទៅនេះខុចបានធ្វើការទាមទារលើកដំបូងជាសាធារណៈ នៅចំពោះមុខសាលាក្ដីនោះដើម្បីសុំអោយមានការដោះលែងរូបគាត់ស្ថិតនៅក្រោយឃុំជាបណ្ដោះអាសន្ន ។ សាវនាការរបស់គាត់ឈរលើស្ថានភាពផ្ទុយគ្នាទៅនឹងដំណើរការនៃប្រព័ន្ធតុលាការភាគច្រើនក្នុងប្រទេសកម្ពុជា ។
ជាទូទៅចុងចោទមិនអាចសុំអោយមានមេធាវីការពារក្ដីបានទេ ប៉ុន្តែប្រសិនបើគេអាចសុំបាននោះគេនិងមិនត្រូវបានអនុញ្ញាតិអោយជួបមេធាវីមុនការនាំខ្លួនទៅកាន់តុលាការនោះទេ ។

នៅក្នុងកំឡុងពេលកាត់ទោស គេបានដឹងថាចៅក្រមជំនុំជំរះបានបដិសេធតាមទំនើងចិត្តទៅនិងភស្តុតាង ដែលចុងចោទលើកយកមកសារភាពហើយមិនត្រឹមតែប៉ុណ្ណោះចៅក្រមជាអ្នកសសេរសាលក្រមទុកជាមុន សំរាប់សាវនាការតុលាការនោះ ។នៅក្នុងករណីនយោបាយមានភាពរសើបជាច្រើនដែលពេលនោះ ចៅក្រមតែងតែទទួលការណែនាំអោយធ្វើតាមពីអ្នកនយោបាយជាន់ខ្ពស់និងពីក្រុមអ្នកជំនិតរបស់រដ្ឋាភិបាល ។ប្រជាជនខ្មែរភាគច្រើនយល់ឃើញថាតុលាការមិនមែនជាកន្លែងស្វែងរកយុត្តិធម៌នោះទេ ។ហើយដំណើរការក្ដីករណីព្រហ្មទ័ណ្ឌ និង ករណីរដ្ឋប្បវេណីអ្នកដែលមានលុយនិងមានអំណាច តែងតែជាអ្នកមានអត្តិភាព ។

នៅពេលដែលអ្នកដាក់ពាក្យប្ដឹងជាអ្នកមានទ្រព្យសម្បត្តិ មានខ្សែរយៈ បក្សពួកល្អនៅចំពោះមុខតុលាការ ពេលនោះចៅក្រមតែងតែដេញថ្លៃថាអ្នកណាជាអ្នកមានសំណាងក្នុងការឈ្នះក្ដីនោះហើយនិងដើម្បីទទួលនូវការសូកប៉ាន់ខាងលុយកាក់ ។ បទពិសោធន៍របស់ប្រជាជនខ្មែរជាច្រើន ក្នុងប្រព័ន្ធយុត្តិធម៌គឺជា ការស្វែងរកទ្រូាបញ្ជីរណាមួយដើម្បី

សូកប៉ាន់ក្នុងភាពសង្ឃឹមថាចៅក្រមនិង សំរេចអោយឈ្នះទៅលើភាគីណាមួយនោះ ។ ប្រសិនបើលោកអ្នកគ្មានប្រាក់ទេនោះលោកអ្នកនិងមិន អាចឈ្នះក្តីបានឡើយ ។

នៅក្នុងបរិយាកាសនៃសាលាក្តីខ្មែរក្រហមក្នុងប្រទេសកម្ពុជាកំពុងកើតមានឡើង ។ ជនដែលត្រូវបានគេចាប់ខ្លួនទាំង5នាក់ដ៏សំខាន់ផ្តល់នូវភាពសង្ឃឹមអ្នកខ្លះចំពោះដំណើរការជាប់គាំងដ៏យូរផ្ទៃងក្នុងការនាំខ្លួនអតីតៈមេដឹកនាំខ្មែរក្រហមទាំងនោះទៅតុលាការ គឺចាប់ទទួលផលនៅចុងបញ្ចប់ ។ ប៉ុន្តែនៅពេលក្រុមប្រទេសម្ចាស់ជំនួយអន្តរជាតិកំពុងពិចារណាទៅលើការស្នើរសុំថវិកាចំនួន1 7 0 លានដុល្លារបន្ថែមក្នុងសប្តាហ៍ខាងមុខនេះ ក្រុមប្រទេសផ្តល់ជំនួយទាំងនេះគួរតែប្រុងប្រយ័ត្ននិងទទូចអោយមានការកែទំរង់ដ៏សំខាន់មួយ
មុនធ្វើការផ្តល់ជំនួយបន្ថែមទៀត ។

សាលាក្តីខ្មែរក្រហម ត្រូវបានគេបង្កើតឡើងជាសាលាក្តីពិសេសមួយជាមួយប្រព័ន្ធតុលាការកម្ពុជាសំរាប់កាត់ក្តីមេដឹកនាំជាន់ខ្ពស់និងអ្នកដែលទទួលខុសត្រូវខក្រិដ្ឋកម្មទាំងឡាយដែលកើតមានឡើងក្នុងឆ្នាំ1975 ដល់ ឆ្នាំ1979 ។ អង្គការសហប្រជាជាតិជាអ្នកផ្តួចផ្តើមជំទាស់មិនអោយមានការរៀបចំនូវតុលាការកូនកាត់នោះ ដោយសារតែមានការភ័យខ្លាចដែលថារដ្ឋាភិបាលប្រទេសកម្ពុជាអាចព្យាយាមគ្រប់គ្រងសាលាក្តីនោះនិងអាចធ្វើឯករាជ្យភាពរបស់សាលាក្តីនោះមានការដាក់កំរិត ។ ប្រព័ន្ធតុលាការក្នុងប្រទេសកម្ពុជាត្រូវបានគេដឹងយ៉ាងទូលំទូលាយថាមានកង្វះខាតឯករាជ្យភាពរបស់ខ្លួនដោយសារមានជាប់ទាក់ទងអំពើពុករលួយដែលមិនអាចទប់បាន និងកំរិតវិជ្ជាជីវៈការងារនៅមានកំរិតទាប ។

បញ្ហាដែលនៅមានទាំងនេះ គឺមានសារសំខាន់ដល់ផ្នែកដ៏ទៃទៀតនៃសាលាក្តីខ្មែរក្រហមទាំងអស់ដើម្បីបំពេញតួនាទីត្រឹមត្រូវដើម្បីជាឱកាសមួយធ្វើអោយដំណើរការតុលាការ មានកេរ្តិ៍ឈ្មោះល្អនៅពេលខាងមុខ ។

បញ្ហាដ៏ធំមួយក្នុងចំណោមបញ្ហាមួយចំនួនដែលមិនទាន់ត្រូវបានគេដោះស្រាយនោះ ថាតើសាលាក្តីខ្មែរក្រហម នឹងមានបំណងត្រឹមណាធ្វើតាមភស្តុតាង និង កំណត់មនុស្សបន្ថែមសំរាប់ការស៊ើបអង្កេតនិងការជំនុំជំរះ ។

រដ្ឋាភិបាលប្រទេសកម្ពុជាត្រូវការជំនុំជំរះតែមនុស្ស ពីរបីនាក់ប៉ុណ្ណោះដើម្បីបង្ហាញថាបានធ្វើការរួមចំណែកធ្វើអោយខ្មែរក្រហមអោយទទួលខុសត្រូវដោយពុំចាំបាច់កាត់ទោសដល់សមាជិករដ្ឋាភិបាលខ្មែរសព្វថ្ងៃដែលធ្លាប់ជាសមាជិកអតីតខ្មែរក្រហម ។ ប៉ុន្តែថាតើសាលាក្តីខ្មែរក្រហម អាចគេជឿទុកចិត្តបានទេបើគ្រាន់តែធ្វើកាត់ទោសតែមនុស្សពីរបីនាក់ដែលបានជ្រើសរើសជាមុននោះ? គំរោងថវិការបស់សាលាក្តីខ្មែរក្រហមបានបង្ហាញទៅម្ចាស់ជំនួយកាលពីខែមករាថាមនុស្ស 3 នាក់ទៀតនឹងត្រូវគេកាត់អោយជាប់ទោស ។ ក្នុងខណៈពេលដែលមនុស្សទាំងប្រាំនាក់ត្រូវបានគេចោទប្រកាន់ក្នុងរយៈពេលកន្លងមក នេះគឺសុទ្ធតែជាមនុស្សសំខាន់ៗខណៈនោះចំនួននៃការចោទប្រកាន់ទៅលើជនដៃដល់មួយចំនួនដែលរួមបញ្ចូលទាំងក្រុមមន្ត្រីរដ្ឋាភិបាលខ្មែរក្រហមកណ្តាលដូចជាក្រុមមន្ត្រីយោធាជាន់ខ្ពស់ និង ក្រុមអាជ្ញាធរមូលដ្ឋានដែលកំពុងបន្តរស់រានមានជីវិតយ៉ាងមានសេរីភាពក៏មានចំនួនច្រើនផងដែរ ។ក្រុមអ្នកផ្តល់ជំនួយត្រូវធានាអោយបានច្បាស់ថាសាលាក្តីខ្មែរក្រហមមានការខុបត្ថម្ភផ្នែកហរិញ្ញវត្ថុហើយចាំបាច់ណាស់ត្រូវអោយមានឯករាជ្យភាព ដើម្បីនាំខ្លួនចុងចោទបន្ថែមទៀតទៅតុលាការដើម្បីរកយុត្តិធម៌ អោយជនរងគ្រោះ ។

បញ្ហាផ្សេងៗទៀតដែលសាលាក្តីខ្មែរក្រហមកំពុងជួបប្រទះនោះគឺរួមបញ្ចូលទាំងតម្រូវការអោយមានកម្មវិធីការពារជនរងគ្រោះ និងសាក្សីមួយដោយមិនចាំបាច់ធ្វើអោយមានការលំបាកក្នុងដំណើរការជំនុំជំរះវីក៏អនុញ្ញាតិអោយជនរងគ្រោះចូលរួមឆ្លើយបំភ្លឺដោយមានសុវត្ថិភាពជាភាគីរដ្ឋប្បវេណី ។ សំនួរជាច្រើនក៏ត្រូវបានលើកឡើងរួចរាល់ហើយដែរថា សាលាក្តីខ្មែរក្រហម អាចការពារសាក្សីដែលចូលរួមឆ្លើយបំភ្លឺកាលពីសប្តាហ៍មុនដូចមេចក្នុងផ្នែកមួយនៃការស៊ើបអង្កេតនៅពេលដែលក្រុមការងារ ផ្នែកសាក្សីរបស់សាលាក្តីខ្មែរក្រហមពុំធ្វើការនោះ ។

មូលនិធិជាច្រើនក៏ត្រូវការជួលអ្នកស៊ើបអង្កេតអោយបានគ្រប់គ្រាន់ ដើម្បីអនុវត្តអោយរលូនហើយការស៊ើបអង្កេតមានកំរិតខ្ពស់ហើយក៏ត្រូវអោយមានការបង្កើតយុទ្ធនាការដើម្បីចុះផ្សព្វផ្សាយដល់សាធារណៈដើម្បីអោយប្រជាជនខ្មែរទទួលបាននូវការយល់ដឹងអំពីដំណើរការនោះ ។គេក៏ត្រូវបង្ហាញផងដែរនូវការចោទប្រកាន់ទាំងឡាយពីអំពើពុករលួយការស៊ីសំណូកនិងភាពខ្វះការគ្រប់គ្រងនៃភាគីកម្ពុជាដែលធ្វើការក្នុងសាលាក្តីនោះ ។

អ្នកសង្កេតការផ្នែកសិទ្ធមនុស្សជាច្រើនបានសួររួចហើយដែលភាពស្របច្បាប់នៃការសំរេចចិត្តខ្លះបានធ្លាក់ទៅដល់សាលាក្តីខ្មែរក្រហម ឯករាជ្យភាព សមត្ថភាព និងការប្តេជ្ញាចិត្តនៃចៅក្រមកម្ពុជាខ្លះ ។ ឧទាហរណ៏កាលពីខែកុម្ភៈ សាលាក្តីខ្មែរក្រហមបានបដិសេធថាលោក **ន័យថុល** ជាមនុស្សពុំមានសមត្ថភាព ។ ជាប្រធានតុលាការយោធា លោក **ន័យថុល** បានកាត់ក្តីលំអៀងជាច្រើនចំពោះអ្នកប្រឆាំងនិងលោកនាយករដ្ឋមន្ត្រីហ៊ុន សែនហើយដែលលក្ខណៈតិចតួចណាស់ក្នុងការកាត់ក្តីផ្អែកទៅលើសិទ្ធដើម្បីការកាត់ក្តីដោយយុត្តិធម៌ ។

*ដោយសារតែមានបញ្ហាទាំងអស់នេះហើយ សាលាក្តីខ្មែរក្រហមចាំបាច់ត្រូវធ្វើកំណែទំរង់ជាបន្ទាន់ ។ មុនធ្វើការផ្តល់មូលនិធិបន្ថែម ម្ចាស់ជំនួយទាំងអស់ត្រូវតែទាមទារអោយមានការទទួលខុសត្រូវអោយបានធំ និងមានគារាំងគំរោងមួយសំរាប់អនុវត្តន៏នូវគ្រឹះនៃកំណែទំរង់នោះអោយកាន់តែមានប្រសិទ្ធភាពសំរាប់ដោះស្រាយការចោតប្រកាន់អំពើពុករលួយហើយកែតម្រង់ភាពខ្វះការគ្រប់គ្រងនិងការដឹកនាំផ្នែករដ្ឋបាលរបស់តុលាការនេះ ។ តុលាការនេះចាំបាច់ត្រូវមានតម្លាភាពថែមទៀត ធ្វើដូច្នេះទើបយុត្តិធម៏នៅក្នុងប្រទេសកម្ពុជាមិនគ្រាន់តែមានភាពជោគជ័យនោះទេ តែភាពជោគជ័យនោះត្រូវធ្វើឡើងនិងទទួលបានដោយប្រជាជនកម្ពុជាផងដែរ ។*

*ជំហ៊ានដំបូងសំខាន់នោះគឺខាងអង្គការសហប្រជាជាតិត្រូវតែតែងតាំងទីប្រឹក្សាជាន់ខ្ពស់ដែលមានជំនាញការទូតនិងមានសមត្ថភាព សំរាប់សាលាក្តីខ្មែរក្រហម ដើម្បីអោយអនុវត្តការផ្លាស់ប្តូរដែលចាំបាច់ហើយសំខាន់ទាំងនោះ ។ អ្នកជំនួយការអន្តរជាតិត្រូវតែធានាថាការអនុវត្តន៍ថ្នាក់ជាតិរបស់ប្រទេសកម្ពុជាគួរតែកើតចេញជាលក្ខណៈនៃគំរូអន្តរជាតិហើយគំរូអន្តរជាតិមិនគួរនៅទាបជាងកំរិតនៃការអនុវត្តន៍ក្នុងស្រុករបស់កម្ពុជានោះទេ ដែលវាអាចធ្វើអោយខូចដល់កិត្តិនាមរបស់អង្គការសហប្រជាជាតិនិងយុត្តិធម៏អន្តរជាតិ ។*

*ប្រសិនបើម្ចាស់ជំនួយនិងអង្គការសហប្រជាជាតិទទូចអោយមានមានកែទម្រង់នោះតុលាការខ្មែរក្រហមនឹងអាចផ្តល់យុត្តិធម៏ដល់ប្រជាជនកម្ពុជាដែលកំពុងរងចាំអស់រយះពេលជាយូរឆ្នាំមកហើយនោះ ។*

*—លោកស្រី* **សារា ខូលិ៍ម** *ជាអ្នកស្រាវជ្រាវ*
*អំពីបញ្ហាកម្ពុជាប្រចាំអង្គការឃ្លាំមើលសិទ្ធមនុស្ស ។*